**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៩៦៦ ... សហវ. ...

ថ្ងៃ... ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

**ជម្រាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារស្ថាបនាស្ពានបេតុងសរសៃដែក ប្រវែង ៤៥ម ទទឹង ៨ម ចំនួន ០១កន្លែង ស្ថាបនាផ្លូវតភ្ជាប់ក្បាលស្ពានសងខាងដោយក្រាលក្រួសក្រហម ប្រវែងសរុប ១០០ម ទទឹង ៨ម ស្ថាបនារូបនាគផុស ចំនួន ០៤ស្លាក ដាក់បង្គោលភ្លើងប្រើពន្លឺព្រះអាទិត្យ ចំនួន ០៨បង្គោល និងបំពាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក ស្ថិតក្នុងភូមិម៉ាក់ឃ្លឿ ឃុំម៉ាក់ឃ្លឿ ស្រុកបវេល ខេត្តបាត់ដំបង។

**យោង** :
- លិខិតលេខ១២៧៧៥ សហវ.អថ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ៦៩៤ សក.អល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូនបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ ដើម្បីធ្វើការងារស្ថាបនាស្ពានបេតុងសរសៃដែក ប្រវែង ៤៥ម ទទឹង ៨ម ចំនួន ០១កន្លែង ស្ថាបនាផ្លូវតភ្ជាប់ក្បាលស្ពានសងខាង ដោយក្រាលក្រួសក្រហម ប្រវែងសរុប ១០០ម ទទឹង ៨ម ស្ថាបនារូបនាគផុស ចំនួន ០៤ស្លាក ដាក់បង្គោលភ្លើងប្រើពន្លឺព្រះអាទិត្យ ចំនួន ០៨បង្គោល និងបំពាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក ស្ថិតក្នុងភូមិម៉ាក់ឃ្លឿ ឃុំម៉ាក់ឃ្លឿ ស្រុកបវេល ខេត្តបាត់ដំបង ក្នុងតម្លៃសរុបចំនួន ១.៧១២.០០០.០០០រៀល (មួយប៊ីលានប្រាំពីររយដប់ពីរលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការផ្តល់បន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**ជូ ទីជិត្ត**

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តបាត់ដំបង
- បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
- នាយកដ្ឋានគោលនយោបាយលទ្ធកម្មសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798